00542284

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

D140/9/5

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៥៥)

ចំពោះមុខ:

ចៅក្រម ប្រាក់ គីមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម នៃយ ថុល

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 06 / 2010
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារបានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

សាធារណៈ: (ដោយកោសលុប)

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែល
បដិសេធសំណើរបស់គាត់ សុំតែងតាំងអ្នកជំនាញផ្នែក [redacted] ន្ថែមមួយរូប
ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ
ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ថី យាម**

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ជនត្រូវចោទ**

អៀង សារី

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

002/19-09-2007-អវតក/កសចស (អបជ ៥៥)

លេខ/No. D140/9/5

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

**ទី ចាន់ឌី**

Mahdev MOHAN

Lima NGUYEN

**គឹម ម៉េងឃី**

**ម៉ុច សុវណ្ណារី**

Elizabeth-Joelle RABESANRATANA

Annie DELAHAIE

Philippe CANONNE

Martine JACQUIN

Fabienne TRUSSES-NAPROUS

Françoise GAUTRY

Isabelle DURAND

Christine MARTINEAU

Laure DESFORGES

Ferdinand DJAMMEN-NZEPA

**ឡោ ជុនធី**

**ស៊ិន សុវ៉ន**

**សំ សុគង់**

**ហុង គឹមសួន**

**គង់ ពិសី**

**គង់ ហេង**

Silke STUDZINSKY

Olivier BAHOUGNE

Marie GUIRAUD

**<u>សហមេធាវីការពារក្តីជនត្រូវចោទ</u>**

**អាង ឧត្តម**

Michael G.KARNAVAS

**<u>សហចៅក្រមស៊ើបអង្កេត</u>**

**យូ ប៊ុនឡេង**

Marcel LEMONDE

Partirck BAUDOUIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET

Pascal AUBOIN

យុង ផានិត

**<u>ដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានអ្នកតំណាង</u>**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែលបដិសេធសំណើរបស់គាត់ សុំតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ថឺ ឃាម" ដែលសហមេធាវីការពារក្តី អៀង សារី ("ជនត្រូវចោទ") បានដាក់ប្តឹងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍លើកទីពីរ")[១]។

## **សាវតា**

១. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើលើកទី៦ សុំបើកកិច្ចស៊ើបអង្កេត" ទៅសហចៅក្រមស៊ើបអង្កេត ("សំណើលើកទី៦ របស់ នួន ជា")[២]។ សំណើលើកទី៦របស់ នួន ជា នេះ បានស្នើសុំឱ្យ "[សហចៅក្រមស៊ើបអង្កេត] ខិតខំប្រឹងប្រែងកំណត់[redacted] ដោយមានជំនួយពីអ្នកជំនាញមានសមត្ថភាព[redacted] (ឬអ្នកជំនាញ)"[៣]។ បន្ថែមពីលើនេះ សំណើនេះបានស្នើសុំឱ្យមានការតែងតាំងអ្នកជំនាញមួយរូប ឬច្រើនរូប[៤]។

---

[១] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែលបដិសេធសំណើរបស់គាត់ សុំតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍ របស់អ្នកជំនាញដែលបានដាក់ជូនដោយលោកស្រី Tabeau និងលោក ថឺ ឃាម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ឯកសារD140/9/1។

[២] សំណើលើកទី៦ សុំបើកកិច្ចស៊ើបអង្កេត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ ឯកសារD113។

[៣] សំណើលើកទី៦ របស់ នួន ជា កថាខណ្ឌ៩។

[៤] សំណើលើកទី៦ របស់ នួន ជា កថាខណ្ឌ១។

២. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានទទួលយកសំណើលើកទី៦ របស់ នួន ជា[5] ដោយបានតែងតាំងបណ្ឌិត Ewa Maria Tabeau និងលោក ថឺ ឃាម ជាអ្នកជំនាញ [redacted] ដើម្បីឱ្យធ្វើរបាយការណ៍កោសល្យវិច័យ ឱ្យបានមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៦[6]។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់របាយការណ៍កោសល្យវិច័យនេះរហូតដល់ថ្ងៃទី៣០ ខែកញ្ញាឆ្នាំ ២០០៩[7]។

៣. នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ "សំណើរបស់លោក អៀង សារី សុំអ្នកជំនាញ[redacted]បន្ថែម" ទៅសហចៅក្រមចៅក្រមស៊ើបអង្កេត ("សំណើលើកទីមួយ")[8]។ សំណើលើកទីមួយនេះលើកមូលដ្ឋានថា បណ្ឌិត Ewa Tabeau ខ្វះអព្យាក្រឹត្យភាព និងសមត្ថភាព ហើយសហចៅក្រមស៊ើបអង្កេតមិនបានពិគ្រោះយោបល់ជាមួយសហមេធាវីការពារក្តីជនត្រូវចោទ មុនពេលធ្វើការតែងតាំងអ្នកជំនាញ[redacted]ទាំងនោះជាមុនទេ[9]។

៤. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានសម្រេចបដិសេធសំណើរបស់ អៀង សារី ("ដីកាសម្រេចលើកទីមួយ")[10]។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា "មិនមានភស្តុតាង និងហេតុផលសមស្របណាមួយ ដែលអាចបង្ហាញអំពីភាពសង្ស័យលើអព្យាក្រឹត្យភាព ឬសមត្ថភាព" របស់បណ្ឌិត Tabeau ឡើយ ហើយសហចៅក្រមស៊ើបអង្កេត

---

[5] ចម្លើយចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរទី៦ (D113) និងចម្លើយមួយផ្នែកចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរទី៥ (D105) ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ឯកសារ D113/2 និងD105/2។

[6] ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ឯកសារD140។

[7] កំណែនៃដីកាចាត់តាំងអ្នកជំនាញត្រឹមត្រូវតាមច្បាប់ដើម ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ឯកសារ D140/1។

[8] សំណើរបស់លោក អៀង សារី សុំអ្នកជំនាញ[redacted]បន្ថែម ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ឯកសារD140/2។

[9] សំណើរបស់លោក អៀង សារី កថាខណ្ឌ៥។

[10] ដីកាសម្រេចទាក់ទងនឹងសំណើសុំចាត់តាំងអ្នកជំនាញការ[redacted]បន្ថែម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D140/3។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បានប្រកាសថា អនុលោមតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង [សហចៅក្រមស៊ើបអង្កេត] មិនមានកាតព្វកិច្ចណាមួយ ដែលត្រូវពិភាក្សាជាមួយនឹងភាគីមុននឹងធ្វើការតែងតាំងអ្នកជំនាញនោះទេ[១១]។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ ("បណ្តឹងឧទ្ធរណ៍លើកទីមួយ")[១២]។ បន្ទាប់ពីការដាក់បណ្តឹងឧទ្ធរណ៍មក បណ្ឌិត Tabeau និងលោក ធី ឃាម បានដាក់របាយការណ៍អ្នកជំនាញ[redacted]រួមគ្នា("របាយការណ៍អ្នកជំនាញ")[១៣]។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះសម្រេចមិនទទួលយកបណ្តឹងឧទ្ធរណ៍លើកទីមួយនេះ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍លើកទីមួយ")[១៤]។

៥. នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សំណើមួយទៀតសុំតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Tabeau និង លោក ធី ឃាម ("សំណើលើកទីពីរ")[១៥]។ សហមេធាវីការពារក្តីបានពន្យល់ថា សំណើលើកទីពីរ "នឹងព្យាយាមពន្យល់ឱ្យបានពេញលេញបន្ថែមទៀតអំពីក្តីព្រួយបារម្ភរបស់ខ្លួនទាក់ទងនឹងអសមត្ថភាព និងភាព-លម្អៀង របស់លោកស្រី Tabeau ឱ្យកាន់តែពិស្តារជាងមុន"[១៦]។ សហមេធាវីការពារក្តីបានស្នើសុំ

---

[១១] ដីកា កថាខណ្ឌ ១៤-១៥។

[១២] បណ្តឹងរបស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចសុំតែងតាំងអ្នកជំនាញបន្ថែម របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ កញ្ញា ឆ្នាំ២០០៩ (បណ្តឹងឧទ្ធរណ៍) ឯកសារ D140/4/1។

[១៣] របាយការណ៍អ្នកជំនាញ[redacted]៖ ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D140/1/1។

[១៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D140/4/5។

[១៥] សំណើរបស់លោក អៀង សារី សុំតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី TABEAU និងលោក ធី ឃាម ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១០ ឯកសារ D140/7។

[១៦] សំណើលើកទី២ កថាខណ្ឌ១៣។

សហចៅក្រមស៊ើបអង្កេតឱ្យ (១) តែងតាំងអ្នកជំនាញ [redacted] បន្ថែមមួយរូប ដើម្បីពិនិត្យឡើងវិញទៅលើខ្លឹមសារ និង (២) ពិគ្រោះយោបល់ជាមួយនឹងសហមេធាវីការពារក្តី មុននឹងធ្វើការតែងតាំងអ្នកជំនាញបន្ថែម។

៦. នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបដិសេធសំណើលើកទីពីរ ("ដីកាសម្រេចលើកទីពីរ")[១៧]។ នៅក្នុងដីកាទីពីរ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យមេធាវីការពារក្តី នៅក្នុងសាលដីការបស់ខ្លួន "ស្នើសុំឱ្យមានការតែងតាំងអ្នកជំនាញមួយរូបដើម្បីធ្វើការពិនិត្យឡើងវិញទៅលើបញ្ហាមួយ ដែលនៅពេលនេះបញ្ហានេះគឺជាបញ្ហាខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ"។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់នៅក្នុងដីកាសម្រេចថា "ចំពោះសំណើ[លើកទីពីរ]នេះ ក៏មានទឡ្ហីករណ៍ដូចគ្នានឹងទឡ្ហីករណ៍ នៃសំណើសុំនាពេលមុនរបស់មេធាវីការពារក្តីទាក់ទិននឹងលក្ខណៈសម្បត្តិរបស់អ្នកជំនាញ ដែលត្រូវបានបដិសេធចោលម្តងរួចហើយ" ហើយខ្លួន"ប្រកាន់យកជំហររបស់ខ្លួនដែលមាននៅក្នុង[ដីកាសម្រេចលើកទីមួយ]"[១៨]។

៧. នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សារណាបណ្តឹងឧទ្ធរណ៍លើកទីពីរ ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) បដិសេធដីកាសម្រេចលើកទីពីរ និង (២) បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតតែងតាំងអ្នកជំនាញ [redacted] បន្ថែមមួយរូប អនុលោមតាមវិធាន ៣១(១០)នៃវិធានផ្ទៃក្នុង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងភាគី។ សហមេធាវីការពារក្តីសន្និដ្ឋានថា "បណ្តឹងឧទ្ធរណ៍ត្រូវតែដាក់ប្តឹង ដោយហេតុថា [សហចៅក្រមស៊ើបអង្កេត] បានសម្រេចដោយមានកំហុសថា មិនមានភស្តុតាង និងហេតុផលសមស្របណាមួយដែលអាចបង្ហាញអំពីភាពសង្ស័យលើអព្យាក្រឹត្យភាព ឬសមត្ថភាពរបស់លោកស្រី Ewa Tabeau ដែលជាអ្នកជំនាញអន្តរជាតិ [redacted] ដែលត្រូវបានចាត់តាំងនេះឡើយ។ សហចៅក្រម

---

[១៧] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើរបស់ អៀង សារី សុំចាត់តាំងអ្នកជំនាញ [redacted] បន្ថែមមួយរូប ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D140/8។

[១៨] ដីកាសម្រេចលើកទីពីរ កថាខណ្ឌ៣។

ស៊ើបអង្កេតក៏ថែមទាំងមានកំហុសផងដែរ នៅពេលខ្លួនមិនបានផ្តល់សំអាងហេតុបញ្ជាក់អំពីមូលហេតុ ដែលខ្លួនមិនគួរតែងតាំងអ្នកជំនាញ [redacted] បន្ថែមមួយរូបទៀត”។

៨. សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍លើកទីពីរនេះឡើយ។

៩. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើកទីពីរ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[១៩]។

១០. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងឧទ្ធរណ៍លើកទីពីរ ព្រមទាំងបញ្ជាក់ថា “សាលដីកាដែលមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍ នឹងចេញនៅពេលសមស្រប”។

## អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ៖

១. “**យល់ឃើញថា** បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

២. **ច្រានចោល**បណ្តឹងឧទ្ធរណ៍នេះ ចាត់ទុកថាឥតបានការ”[២០]។

១១. អង្គបុរេជំនុំជម្រះសូមផ្តល់សំអាងហេតុនៃសាលដីកានៅពេលនេះ៖

## សំអាងហេតុនៃសាលដីកា

[១៩] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ឯកសារ D140/9/3។

[២០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់ខ្លួន សុំតែងតាំងអ្នកជំនាញ [redacted] បន្ថែម ដើម្បីពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍អ្នកជំនាញដាក់ជូនដោយលោកស្រី Ewa Tabeau និងលោក ថី ឃាម ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D140/9/4។

## ក. ច្បាប់ដែលពាក់ព័ន្ធ

១២. សេចក្តីយោងធ្វើឡើងលើវិធាន ៣១ វិធាន ៧៤ និងវិធាន ៧៥ នៃវិធានផ្ទៃក្នុង។

## ខ. ភាពអាចទទួលយកបាន

១៣. នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើកទីពីរ។ ដីកាសម្រេចលើកទីពីរនេះបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃតែមួយ ពោលគឺ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍លើកទីពីរ។ សារណាបណ្តឹងឧទ្ធរណ៍លើកទីពីរ បានដាក់នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ទៅតាមរយៈពេលកំណត់ ដូចដែលមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

១៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា បណ្តឹងឧទ្ធរណ៍លើកទីពីរនេះ បានដាក់ប្តឹង "ដោយអនុលោមតាមវិធាន ៣១(១០) និងវិធាន ៧៤(៣)(ង) នៃវិធានផ្ទៃក្នុង" និងដោយយោងលើសំណើសុំ "តែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើវិញលើខ្លឹមសារ" នៃរបាយការណ៍របស់អ្នកជំនាញដែលមានស្រាប់"។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា "វិធានផ្ទៃក្នុងបានអនុញ្ញាតឱ្យមេធាវីការពារក្តីស្នើសុំឱ្យមានការតែងតាំងអ្នកជំនាញមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើបញ្ហាមួយ ដែលនៅពេលនេះ បញ្ហានេះ គឺជាបញ្ហានៃខ្លឹមសាររបាយការណ៍របស់អ្នកជំនាញ"[២១]។

## គ. បទដ្ឋាននៃការពិនិត្យឡើងវិញ

[២១] សាលដីការបស់អង្គបុរេជំនុំជម្រះ ស្តីពីបណ្តឹងឧទ្ធរណ៍លើកទីមួយ កថាខណ្ឌ២២។ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែលបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញ* [redacted] *បន្ថែមមួយរូបដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ថឺ ឃាម*

១៥. បណ្តឹងឧទ្ធរណ៍នេះដាក់ប្តឹងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចបដិសេធសំណើរបស់សហមេធាវីការពារក្តីសុំតែងតាំងអ្នកជំនាញបន្ថែមមួយរូប ដើម្បីពិនិត្យឡើងវិញលើរបាយការណ៍របស់អ្នកជំនាញដែលមានស្រាប់។ បណ្តឹងឧទ្ធរណ៍នេះបានចោទប្រកាន់ថាសហចៅក្រមស៊ើបអង្កេតបានសម្រេចដោយមានកំហុសថា មិនមានភស្តុតាង និងហេតុផលសមស្របណាមួយ ដែលអាចបង្ហាញអំពីភាពសង្ស័យលើអព្យាក្រឹត្យភាព ឬសមត្ថភាពរបស់អ្នកជំនាញមួយរូប ហើយសហចៅក្រមស៊ើបអង្កេតក៏ថែមទាំងមានកំហុសផងដែរ នៅពេលខ្លួនមិនបានផ្តល់សំអាងហេតុបញ្ជាក់អំពីមូលហេតុ ដែលខ្លួនមិនគួរតែងតាំងអ្នកជំនាញ[redacted]បន្ថែមមួយរូបទៀត។ សហមេធាវីការពារក្តីមិនបានសន្និដ្ឋានពាក់ព័ន្ធនឹងបទដ្ឋាន នៃការពិនិត្យឡើងវិញ ដែលអាចអនុវត្តបានចំពោះកំហុសទាំងឡាយ ដូចបានចោទប្រកាន់នៅក្នុងបណ្តឹងឧទ្ធរណ៍លើកទីពីរឡើយ។

១៦. វិធានផ្ទៃក្នុងមិនមានចែងអំពីបទដ្ឋាននៃការពិនិត្យឡើងវិញ លើបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត តាមសំណើដែលដាក់ជូនដោយភាគីអនុលោមតាមវិធាន ៥៥(១០) និងវិធាន ៣១(១០) នៃវិធានផ្ទៃក្នុងឡើយ។ សំណើដែលភាគីបានដាក់ ទៅតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង មានលក្ខណៈស្រដៀងគ្នានឹងសំណើ ដែលបានដាក់ទៅតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដោយសំណើទាំងនេះស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបង្គាប់ ឬចាត់វិធានការ(នានា) ដែលខ្លួនយល់ឃើញថា ចាំបាច់ នៅក្នុងការដឹកនាំការស៊ើបអង្កេត។ យោងតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("សាលដីកាលើឃ្លាំងផ្ទុកឯកសាររួម")[២២] អង្គបុរេជំនុំជម្រះនៅពេលពិនិត្យមើលបទដ្ឋាននៅក្នុងយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិនានាបានរកឃើញថា ដីកាសម្រេចបែបនេះនឹងយកមកពិនិត្យតែចំណុចទាក់ទិននឹងការសម្រេច ថាតើសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវដែរឬទេ

---

[២២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ២២-២៧។

00542294



ដោយអនុវត្តតាមលក្ខណាវិនិច្ឆ័យនៅក្នុង "សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំចំពោះសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងលើការតែងតាំងមេធាវីការពារក្តី" នៅក្នុងរឿងក្តី *Milosčvić ទល់នឹងរដ្ឋអាជ្ញា* ("សាលដីកាលើ Milosčvić")[២៣] ដែលសម្រេចដោយតុលាការកំពូលនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("សាលាក្តីយូហ្គោស្លាវី")។ លក្ខណៈវិនិច្ឆយនៅក្នុងសាលាដីកា Milosčvić គឺ៖

> "អង្គជំនុំជម្រះ នឹងច្រានចោលការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ប្រសិនបើសេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ បានផ្អែកលើ (១) ការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន" (២) ការសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះលើអង្គហេតុ ឬ (៣) ភាពអយុត្តិធម៌ និងភាពមិនសមហេតុផល ដែលនាំឱ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិ របស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមិនមានការភ័ន្តច្រឡំលើអង្គច្បាប់ ឬការភ័ន្តច្រឡំលើការរកឃើញអង្គហេតុដោយច្បាស់ក្រឡែត ទេនោះ វិសាលភាពនៃការពិនិត្យមើលបណ្តឹងឧទ្ធរណ៍ឡើងវិញ នឹងមានលក្ខណៈកម្រិតពោលគឺ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះមិនគួរចាត់តាំងមេធាវីការពារក្តីឱ្យលោក *Milosčvić* ក៏ដោយ ក៏សេចក្តីសម្រេចរបស់តុលាការជាន់ក្រោមនៅមានអានុភាព លុះណាតែសេចក្តីសម្រេចនោះមានភាពមិនសមហេតុផលទាល់តែសោះ ដែលបង្ខំឱ្យមានការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ"[២៤]។

១៧. បទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិនានា ក៏បានបង្ហាញថែមទៀតថា លក្ខណៈវិនិច្ឆយដូចគ្នា ត្រូវបានអនុវត្តនៅពេលធ្វើការពិនិត្យមើលឡើងវិញលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹង

---

[២៣] ***រឿងក្តី*** *Milosevic* ***តទល់នឹង រដ្ឋអាជ្ញា សំណុំរឿងលេខ*** IT 02-54-AR73.7 "សាលដីកាលលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការចាត់តាំងក្រុមមេធាវីការពារក្តី" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤។

[២៤] សាលដីកាក្នុងរឿងក្តី *Milosevic* កថាខណ្ឌ៩-១០ (ជើងទំព័រត្រូវបានលុប)។

ដីកាសម្រេចលើសំណើទាំងឡាយ ដែលមានលក្ខណៈស្រដៀងគ្នានឹងសំណើដូចដែលបានដាក់ជូនតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង[២៥]។

## ឃ. ការពិចារណា

### I. កំហុសនៃអង្គហេតុដែលបានចោទប្រកាន់:

១៨. សហមេធាវីការពារក្តីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរថា សហចៅក្រមស៊ើបអង្កេត “មានកំហុសក្នុងការសម្រេចថា មិនមានភស្តុតាង និងហេតុផលសមស្របណាមួយដែលអាចបង្ហាញអំពីភាពសង្ស័យលើអនាគតិ ឬ សមត្ថភាពនៃអ្នកជំនាញផ្នែកប្រជាសាស្ត្រអន្តរជាតិ”[២៦]។ សហមេធាវីការពារក្តីពន្យល់ថា មេធាវីការពារក្តី“សំអាងភាគច្រើននៃការរិះគន់របស់ខ្លួននៃការបដិសេធរបស់ ក.ស.ច.ស នៃសំណើរបស់ខ្លួនទាក់ទងនឹងការបដិសេធរបស់ ក.ស.ច.ស ចំពោះសំណើលើកទីមួយ តាមរយៈដីកាសម្រេចលើកទីមួយ។ នេះដោយសារតែដីកានោះមានលក្ខណៈខ្លីពេក ហើយគ្រាន់តែបញ្ជាក់ទៅលើដីកាទីមួយតែប៉ុណ្ណោះ”[២៧]។

១៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងដីកាទីពីរ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា “ទឡ្ហីករណ៍នៃសំណើសុំនៅពេលនេះ ដូចគ្នានឹងទឡ្ហីករណ៍នៃសំណើសុំនាពេលមុនរបស់មេធាវីការពារក្តី ដែលត្រូវបានបដិសេធចោលម្តងរួចហើយ” [២៨] និងនៅក្នុងដីកាទីមួយ សហចៅក្រមស៊ើបអង្កេត បានផ្តល់នូវមូលហេតុនៃការបដិសេធសំណើសុំទីមួយដូចខាងក្រោម:

---

[២៥] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Vujadin Popovic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-AR73.2 “សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្សំរបស់មេធាវីការពារក្តី ទាក់ទងនឹងឋានៈរបស់ Richard Butler ក្នុងនាមជាសាក្សីជំនាញ” អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨។

[២៦] បណ្តឹងឧទ្ធរណ៍ ទំព័រ១ កថាខណ្ឌទីមួយ និងកថាខណ្ឌ១៦ ក និង ខ។

[២៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៦ ជើងទំព័រ៣០។

[២៨] ដីកាសម្រេច កថាខណ្ឌ៣។

**"សំអាងហេតុនៃសេចក្តីសម្រេច**

៥. យើងមិនអាចទាញបានទេថា ការងារបច្ចុប្បន្នរបស់លោកស្រី Tabeau នៅក្នុងការិយាល័យរដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី (OTP-ICTY) អាចមានឥទ្ធិពលលើលទ្ធភាពរបស់លោកស្រីក្នុងការតាក់តែងនូវរបាយការណ៍ ដែលមានលក្ខណៈអព្យាក្រឹត្យ សម្រាប់ការិយាល័យសហចៅក្រម ស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (OCIJ-ECCC)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ អតីតប្រទេសយូហ្គោស្លាវី គឺជាតុលាការពិសេស (*Ad Hoc*) មួយ ដែលត្រូវបានបង្កើតឡើងក្រោមបទបញ្ញត្តិនៃជំពូក VII នៃធម្មនុញ្ញសហប្រជាជាតិ ដើម្បីធ្វើការស៊ើបអង្កេតលើបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអតីតប្រទេសយូហ្គោស្លាវី។ អ.វ.ត.ក គឺជាអង្គជំនុំជម្រះ ដែលបង្កើតឡើងនៅក្នុងក្របខណ្ឌ និងក្នុងរចនាសម្ព័ន្ធនៃតុលាការជាតិរបស់ប្រទេសកម្ពុជា និងដែលមានតួនាទីក្នុងការស៊ើបអង្កេតលើបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងដោយមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងដោយជនទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ដូច្នេះ ទាំងកម្មវត្ថុ ភាគី និងអ្នកជម្រះក្តី គឺមានលក្ខណៈខុសគ្នាទាំងស្រុងតែម្តង។

៦. វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើកិច្ចស៊ើបសួររបស់ខ្លួន ដោយអនាគតិ។ វិធាននេះក៏អនុវត្តផងដែរចំពោះអ្នកជំនាញ ដែលចាត់តាំងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ ចំពោះរឿងដែលថា លោកស្រី Tabeau ធ្វើ ការនៅ OTP-ICTY និង រឿងដែលថា មន្ត្រីជាន់ខ្ពស់ពីររូបរបស់ការិយាល័យសហព្រះរាជអាជ្ញា ធ្លាប់បម្រើការងារពីមុននៅ ICTY មិនអាចក្លាយជាហេតុផលមួយគ្រប់គ្រាន់នោះទេ ក្នុងការទាញសេចក្តីសន្និដ្ឋានថា លោកស្រី Tabeau មិនអាចនឹងបំពេញការងាររបស់ខ្លួនប្រកបដោយអនាគតិ នៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ន នៅចំពោះមុខ អ.វ.ត.ក។

00542297



៧. ក្រុមមេធាវីការពារក្ដីបានលើកឡើងថា ដោយហេតុថា អង្គជំនុំជម្រះទី II របស់ ICTY មិនបានធ្វើការយោងទៅដល់របាយការណ៍កោសល្យវិច័យ ដែលដាក់ដោយលោកស្រី Tabeau នៅក្នុងរឿងក្ដី *Simic,* ក.ស.ច.ស មិនគួរចាត់តាំងលោកស្រីជាអ្នកជំនាញនោះទេ។

៨. នៅក្នុងរឿងក្ដី *Simic* អង្គជំនុំជម្រះបានធ្វើសេចក្ដីសន្និដ្ឋានថា របាយការណ៍កោសល្យវិច័យ ដែលដាក់ដោយលោកស្រី Tabeau (និងដោយលោកស្រី Svetlana Radovanovic ដែលជាអ្នកជំនាញការរបស់ក្រុមមេធាវីការពារក្ដី) សុទ្ធតែមិនអាចបញ្ជាក់ការពិតបានចំពោះបញ្ហាដែលទាក់ទងនឹងការបោសសម្អាតជាតិសាសន៍ និងការជម្លៀសប្រជាជនដោយបង្ខំ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានសម្រេចមិនធ្វើការយោងដល់ខ្លឹមសារនៃរបាយការណ៍ទាំងនោះទេ។

៩. ដើម្បីជាការគាំទ្រដល់សំណើសុំរបស់ខ្លួន ក្រុមមេធាវីការពារក្ដីបានលើកឡើងហួសពីអ្វី ដែលមាននៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ នៅក្នុងរឿងក្ដី *Simic*។ អង្គជំនុំជម្រះ មិនបានលើក ឡើងថា ប្រភពឯកសារដែលប្រើប្រាស់ដោយលោកស្រី Tabeau ដើម្បីតាក់តែងរបាយការណ៍របស់ខ្លួន មានលក្ខណៈ "មិនគ្រប់គ្រាន់ជាក់ស្ដែង" នោះទេ[២៩]។ អង្គជំនុំជម្រះ គ្រាន់តែបានបង្ហាញធម្មតាថា ទិន្នន័យមួយចំនួនដែលអ្នកជំនាញបានផ្អែកលើមានលក្ខណៈមិនគ្រប់គ្រាន់ និងថា មិនមានរបាយការណ៍របស់អ្នកជំនាញណាមួយ ដែលបានប្រើប្រាស់ប្រភពទិន្នន័យដែលឆ្លើយតបទៅនឹងអង្គហេតុ ដែលជាកម្មវត្ថុនៃរឿងក្ដីនោះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះបានលើកឡើងថា "... ភស្ដុតាងដែលបានបង្ហាញដោយអ្នកជំនាញទាំងពីរសុទ្ធតែមិនអាចធ្វើការបញ្ជាក់បែងចែកបាន ថាតើជនស៊ីវិលត្រូវបានជម្លៀសចេញដោយស្ម័គ្រចិត្ត ឬដោយបង្ខំ"[៣០]។ ដូច្នេះ នេះមិនមែនជាការរិះគន់ចំពោះ សមត្ថភាពរបស់អ្នកជំនាញនោះទេ។

១០.សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ II នៅក្នុងរឿងក្ដី *Simic* ទាក់ទងនឹងទម្ងន់ដែលចៅក្រមផ្ដល់ឲ្យចំពោះភស្ដុតាង ដែលផ្ដល់ឡើងដោយភាគី វាមិនអាចក្លាយ

---

[២៩] ប្រៀបធៀប សំណើ កថាខណ្ឌ១៧ *in fine*។

[៣០] *រឿងក្ដី Simić និងអ្នកផ្សេងទៀត* (TC II, ICTY) សាលក្រម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៣៤ *in fine*។ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីការស្នើសុំរបស់គាត់សុំតែងតាំងអ្នកជំនាញ* [redacted] *បន្ថែមមួយរូបដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ថៃ ហេង*

ជាហេតុផលមួយគ្រប់គ្រាន់ ក្នុងការដែលត្រូវដកទំនុកចិត្តលើលោកស្រី Tabeau (ឬ លោកស្រី Radovanovic) ក្នុងឋានៈជាអ្នកជំនាញ ដោយផ្អែកលើមូលដ្ឋាននៃបញ្ហាអសមត្ថភាពនោះទេ។

១១. ក្រុមមេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា ដោយហេតុថាលោកស្រី Radovanovic បានធ្វើការរិះគន់អំពីសមត្ថភាពជំនាញរបស់លោកស្រី Tabeau នៅក្នុងរបាយការណ៍របស់គាត់ ចំពោះក្តី *Prlic*[៣១] ដូច្នេះវាជារឿងមិនសមស្របទេក្នុងការដែល ក.ស.ច.ស ធ្វើការពឹងផ្អែកតែលើរបាយការណ៍កោសល្យវិច័យរបស់លោកស្រី Tabeau តែឯកឯងនោះ។

១២. នីតិវិធីដែលអនុវត្តនៅចំពោះមុខ ICTY គឺផ្អែកជាសំខាន់លើប្រព័ន្ធច្បាប់កំមិនឡូ ដែលក្នុងនោះ វាជារឿងធម្មតាទេ ដែលយោបល់របស់អ្នកជំនាញ ដែលចាត់តាំងដោយភាគី តែងតែមានភាពខុសគ្នានោះ។ ដូច្នេះ ចំពោះហេតុដែលថា អ្នកជំនាញម្នាក់ដែលចាត់តាំងដោយភាគីប្រឆាំង បានធ្វើការរិះគន់លើសមត្ថភាពរបស់លោកស្រី Tabeau វាមិនមែនជាហេតុផលគ្រប់គ្រាន់ និងសមរម្យទេក្នុងការដែលត្រូវទាញសេចក្តីសន្និដ្ឋានថា លោកស្រី Tabeau អសមត្ថភាពនៅក្នុងមុខ ជំនាញរបស់គាត់នោះ។

១៣. ជាងនេះទៅទៀត វាមិនមែនជាការពិតទេ ដែលថា ក.ស.ច.ស ធ្វើការយោងទៅដល់តែលទ្ធផលកោសល្យវិច័យរបស់លោកស្រី Tabeau តែឯកឯងនោះ។ ជាក់ស្តែង ក.ស.ច.ស ក៏បាន ចាត់តាំងអ្នកជំនាញកោសល្យវិច័យជាតិចំនួន០១ រូបផងដែរ ដើម្បីឲ្យបំពេញការងារជាមួយលោកស្រី Tabeau។

១៤. អនុលោមតាមអ្វីដែលបានរៀបរាប់មកខាងលើនេះ យើងសន្និដ្ឋានបានថា មិនមានភស្តុតាង និងហេតុផលសមស្របណាមួយ ដែលអាចបង្ហាញអំពីភាពសង្ស័យលើអព្យាក្រឹត្យភាព ឬសមត្ថភាព របស់លោកស្រី Tabeau ចំពោះរឿងដែលលោកស្រីត្រូវបានចាត់តាំងជាអ្នកជំនាញនោះទេ។ សេចក្តីសន្និដ្ឋានបែបនេះ ក៏អាចត្រូវបានបញ្ជាក់

---

[៣១] *រឿងក្តី Prlic* (TC, ICTY) របាយការណ៍អ្នកជំនាញរបស់បណ្ឌិត Svetlana Radovanović ត្រូវបានដាក់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨។

បន្ថែមបានផងដែរ តាមរយៈគុណភាព និងបរិមាណនៃ ការបោះពុម្ពផ្សាយស្នាដៃរបស់លោកស្រី សញ្ញាបត្រសិក្សាដែលគាត់មានមុខវិជ្ជាដែលគាត់បង្រៀន សន្និសីទដែលគាត់ធ្លាប់បានចូលរួម និងការណ៍ដែលលោកស្រីធ្លាប់ត្រូវបានគេចាត់តាំងជាអ្នកជំនាញនៅក្នុងរឿងក្តីជាច្រើនរបស់ ICTY”[៣២]។

២០. ដូចដែលសហចៅក្រមស៊ើបអង្កេតបានពន្យល់ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ឧទាហរណ៍ទាំងឡាយដែលបានប្រើប្រាស់ដោយសហមេធាវីការពារក្តីនៅក្នុងសំណើលើកទីមួយ ដើម្បីបង្ហាញភស្តុតាងអំពីភាពលម្អៀងរបស់លោកស្រី Tabeau តំណាងឱ្យការអង្កេតអំពីលក្ខណៈទូទៅ ជាជាងភស្តុតាងជាក់ស្តែង ដែលពាក់ព័ន្ធច្បាស់លាស់ទៅនឹងករណីដែលបានលើកឡើង។ ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់ថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើឆន្ទានុសិទ្ធរបស់ខ្លួននៅក្នុងការសម្រេចថា មិនមានភស្តុតាង និងហេតុផលសមស្របណាមួយដែលអាចបង្ហាញអំពីភាពសង្ស័យលើអនាគតិ ឬ សមត្ថភាពនៃអ្នកជំនាញផ្នែកប្រជាសាស្ត្រនោះទេ។

២១. នៅក្នុងសំណើលើកទីពីរ សហមេធាវីការពារក្តីបានលើកឡើងទៅកាន់សហចៅក្រមស៊ើបអង្កេតថា ខ្លួន“នឹងព្យាយាមពន្យល់ឱ្យបានពេញលេញបន្ថែមទៀត អំពីក្តីព្រួយបារម្ភរបស់ខ្លួនទាក់ទងនឹងអសមត្ថភាព និងភាពលម្អៀងរបស់លោកស្រី Tabeau ឱ្យកាន់តែពិស្តារជាងអ្វីដែលមាននៅក្នុងសំណើមុនរបស់ខ្លួន [សំណើលើកទីមួយ]”[៣៣]។

២២. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីការពារក្តីនៅក្នុងសំណើលើកទីពីររបស់ខ្លួនបានដាក់យុត្តិសាស្ត្រផ្សេងទៀតមួយចំនួនដែលបានមកពីតុលាការ ICTY នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួន។ សហមេធាវីការពារក្តីលើកឡើងថា តុលាការ ICTY “នឹងដកហូតសិទ្ធិអ្នកជំនាញដែរ ប្រសិនបើគាត់ត្រូវបានគេចាត់ទុកថា មានភាពជិតស្និទ្ធ

[៣២] ដីកាសម្រេចលើកទីមួយ កថាខណ្ឌ៥-១៤ (*ជើងទំព័រត្រូវបានលុប*)។

[៣៣] សំណើលើកទីពីរ កថាខណ្ឌ១៣។

ខ្លាំងជាមួយនឹងភាគីណាមួយ ក្នុងករណីត្រូវធ្វើកោសល្យវិច័យ ដោយមិនលម្អៀងនោះ"[៣៤]។ ឧទាហរណ៍នេះត្រូវបានដកស្រង់ចេញមកពីការជំនុំជម្រះរឿងក្តី *Đorđevic* ដែលអ្នកជំនាញ ដែលពាក់ព័ន្ធបានចូលរួម "នៅក្នុងការរៀបចំករណីការកាត់ទោស" នៅក្នុងរឿងក្តីដដែល។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការប្រើប្រាស់សិទ្ធិអំណាចនេះរបស់សហមេធាវីការពារក្តី ធ្វើឱ្យខូចខាតដល់គោលបំណងរបស់ខ្លួន ពីព្រោះវាបង្ហាញថា ចំណុចចាប់ផ្តើមនៃការបញ្ជាក់ឱ្យបានគ្រប់គ្រាន់អំពីភស្តុតាង ដែលត្រូវយកទៅប្រើប្រាស់ដើម្បីបញ្ជាក់អះអាងអំពីភាពលម្អៀងរបស់អ្នកជំនាញ នៅក្នុងការអនុវត្តជាអន្តរជាតិ ត្រូវបានកំណត់ខ្ពស់ជាងការអះអាង ដែលធ្វើឡើងដោយសហមេធាវីការពារក្តីចំពោះសហចៅក្រមស៊ើបអង្កេត។ មិនដូចនៅក្នុងរឿងក្តី *Đorđevic* នោះទេ សហមេធាវីការពារក្តីគ្មានភស្តុតាងជាក់ស្តែង ដើម្បីបង្ហាញថា លោកស្រី Tabeau មានការពាក់ព័ន្ធកាលពីមុននៅក្នុងករណីពិសេសនេះ នៅចំពោះមុខ ក.ស.ច.ស/ អ.វ.ត.ក ដែលអាចជាមូលហេតុសមស្របបណ្តាលឱ្យកើតមានទូវភាពលម្អៀង របស់លោកស្រីនោះឡើយ។ បន្ទាប់ពីបានពិចារណាអំពីចំណុចចាប់ផ្តើមដែលមានកម្រិតខ្ពស់នេះ និងការខកខានមិនបានផ្តល់ភស្តុតាង ដើម្បីបង្ហាញអំពីភាពលម្អៀងពិតប្រាកដ ឬតាមការសន្មត អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវនៅក្នុងដីកាទីពីរដែលមិនផ្លាស់ប្តូរសេចក្តីសន្និដ្ឋាន ដែលខ្លួនបានធ្វើនៅក្នុងដីកាទីមួយ។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា នៅក្នុងសំណើលើកទីពីររបស់ខ្លួន សហមេធាវីការពារក្តី មិនបានយោងជាក់លាក់ទៅលើឧទាហរណ៍ទាំងឡាយដែលបានមកពីរបាយការណ៍របស់អ្នកជំនាញនោះទេ សហមេធាវីការពារក្តីគ្រាន់តែបានលើកឡើងយ៉ាងខ្លីថា "វិការៈនៅក្នុងរបាយការណ៍ ដែលមិនលម្អៀង និងសត្យានុម័តដែលត្រូវបានគេសន្មតនោះ នឹងទំនងជាធ្វើឱ្យបុគ្គលណា ដែលមិនមានបទពិសោធន៍នៅក្នុងការប្រមូលទិន្នន័យ[redacted] មើលឃើញច្បាស់លាស់ឡើយ"[៣៥]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរ សហមេធាវីការពារក្តីលើកឡើងថា

---

[៣៤] សំណើលើកទីពីរ កថាខណ្ឌ១៧។

[៣៥] សំណើលើកទីពីរ កថាខណ្ឌ១២។

“របាយការណ៍របស់អ្នកជំនាញ[redacted]បង្ហាញថា លោកស្រី Tabeau មានភាពលម្អៀង ទៅលើការប៉ាន់ស្មានដែលបង្ហាញ[redacted] - ដែលជាការបង្ហាញនូវកង្វះភាពអនាគតិរបស់ លោកស្រី Tabeau”[៣៦]។ ជាងនេះទៀត នៅក្នុងបណ្តឹងឧទ្ធរណ៍លើកទីពីរ សហមេធាវីការពារក្តីបាននិយាយពីកំហុស ដែលបានចោទប្រកាន់ផ្សេងទៀតនៅក្នុងរបាយការណ៍របស់អ្នកជំនាញ ដោយបានលើកឡើងថា លោកស្រី Tabeau : ខកខានមិនបានធ្វើការស្រាវជ្រាវថ្មី និងមិនបានទាញការវាយតម្លៃដោយផ្ទាល់ខ្លួនរបស់លោកស្រីឡើយ ខកខានមិនបានធ្វើការពន្យល់ថា ប្រភពដែលលោកស្រីបានជ្រើសរើស ដើម្បីធ្វើការអង្កេតនោះត្រូវបានជ្រើសរើសបែបណាឡើយ, បានយល់ច្រឡំអំពីបញ្ហា[redacted] ដោយប្រយោលខកខានមិនបានលើកឡើង អំពីការអនុវត្ត[redacted] នៅក្នុងប្រទេសកម្ពុជាឡើយ[៣៧]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា បញ្ហាទាំងអស់នេះមិនត្រូវបានលើកឡើងនៅក្នុងសំណើលើកទីពីរ ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតឡើយ, ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតគ្មានកាតព្វកិច្ចអ្វីក្នុងការលើកឡើងអំពីការព្រួយបារម្ភទាំងនេះនៅក្នុងដីកាទីពីរនោះទេ។

## II. កំហុសអង្គច្បាប់ដែលបានចោទប្រកាន់:

២៤. នៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរ សហមេធាវីការពារក្តីក៏បានលើកឡើងផងដែរថា សហចៅក្រមស៊ើបអង្កេតមានកំហុស “ដោយមិនបានបញ្ជាក់អំពីមូលហេតុតែមួយគត់ថា ហេតុអ្វីបានជាអ្នកជំនាញ[redacted]បន្ថែមម្នាក់ទៀតមិនគួរត្រូវបានតែងតាំងឱ្យមាន”[៣៨]។

២៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងដីកាទីពីរ ដោយទទួលស្គាល់ថា មេធាវីការពារក្តីនៅតែអាចស្នើសុំឱ្យមានការចាត់តាំងអ្នកជំនាញមួយរូបដើម្បីធ្វើការពិនិត្យឡើងវិញ ទៅលើបញ្ហាមួយ

---

[៣៦] បណ្តឹងឧទ្ធរណ៍លើកទីពីរ កថាខណ្ឌ១៦ ក។

[៣៧] បណ្តឹងឧទ្ធរណ៍លើកទីពីរ កថាខណ្ឌ៤៩-៥២ និង ៥៦/ញ-ខ។

[៣៨] បណ្តឹងឧទ្ធរណ៍លើកទីពីរ កថាខណ្ឌ១៦/គ។

ដែលអ្នកជំនាញបានធ្វើរបាយការណ៍រួចហើយក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា ទឡ្ហីករណ៍នៃសំណើសុំនៅពេលនេះដែលដូចគ្នានឹងទឡ្ហីករណ៍នៃសំណើសុំនាពេលមុនដែលត្រូវបានបដិសេធរួចហើយ និងមិនមានហេតុផលណាមួយធ្វើការកែប្រែជំហរពីមុនរបស់ខ្លួនទេ[៣៩]។ នៅក្នុងដីកាទីមួយ សហចៅក្រមស៊ើបអង្កេតលើកឡើងថា "វាមិនមែនជាការពិតទេដែលថា ក.ស.ច.ស ធ្វើការយោងទៅដល់តែលទ្ធផលកោសល្យវិច័យរបស់លោកស្រី Tabeau តែឯកឯងនោះ។ ជាក់ស្តែង ក.ស.ច.ស ក៏បានចាត់តាំងអ្នកជំនាញកោសល្យវិច័យជាតិចំនួន០១រូបផងដែរ ដើម្បីឱ្យបំពេញការងារជាមួយ លោកស្រី Tabeau"[៤០]។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលហេតុទាំងឡាយដែលបានផ្តល់ ដោយសហចៅក្រមស៊ើបអង្កេត សម្រាប់ការមិនតែងតាំងអ្នកជំនាញ[redacted]បន្ថែមទៀត មានលក្ខណៈគ្រប់គ្រាន់ហើយ។ តាមរយៈការបញ្ជាក់ហេតុផលនៅក្នុងដីកាទីពីរ វាក៏បង្ហាញច្បាស់លាស់ផងដែរថា គ្មានហេតុផលណាមួយ ដើម្បីពិចារណាអំពីការតែងតាំងអ្នកជំនាញ[redacted]បន្ថែមទៀតនោះឡើយ ក្រោមកាលៈទេសៈនេះ នៅពេលដែលគោលបំណងនៃសំណើសុំតែងតាំងអ្នកជំនាញបន្ថែម "ដើម្បីធ្វើការពិនិត្យឡើងវិញនូវខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ"[៤១] រីឯមូលដ្ឋាន[៤២] សម្រាប់សំណើសុំនេះក៏មិនត្រូវបានរកឃើញថាត្រូវបានលើកឡើងនោះដែរ។

២៦. នៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរ សហមេធាវីការពារក្តីលើកឡើងថា ទោះបីជាមានក្តីព្រួយបារម្ភដែលបានលើកឡើងអំពីភាពអនាគតិក៏ដោយ ការបដិសេធមិនតែងតាំងអ្នកជំនាញបន្ថែមទៀតរបស់សហចៅក្រមស៊ើបអង្កេតរំលោភទៅលើសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌[៤៣]។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីការពារក្តីមិនបានលើក

---

[៣៩] ដីកាសម្រេចលើកទីពីរ កថាខណ្ឌ៣។

[៤០] ដីកាសម្រេចលើកទីមួយ កថាខណ្ឌ១៣។

[៤១] សំណើលើកទីពីរ សូមមើល ចំណងជើង និង សេចក្តីបញ្ចប់។

[៤២] ភាពអនាគតិដែលបានលើកឡើងរបស់អ្នកជំនាញមួយរូបក្នុងចំណោមអ្នកជំនាញនានា។

[៤៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទីមួយ និងកថាខណ្ឌ១៧-១៩ និង ៥៧។

00542303

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥៥)

លេខ/No. D140/9/5

នូវទឡ្ហីករណ៍នេះទៀតទេ, ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនចាំបាច់ពិចារណាទឡ្ហីករណ៍នេះទៀតឡើយ។

២៧. អាស្រ័យលើមូលហេតុទាំងអស់ដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចសេចក្តីដូច ការប្រកាសនៅក្នុងការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០**

**ចៅក្រមអង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **នីយ ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គឹមសាន**